**ក្រសួងអប់រំ យុវជន និងកីឡា**

**នាយកដ្ឋានគោលនយោបាយ**

អត្ថបទស្រាវជ្រាវប្រតិបត្តិ

# មូលហេតុដែលនាំឱ្យសិស្សនៅវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេសព្រះរាជសម្ភារចូលរៀនថ្នាក់វិទ្យាសាស្ត្រតិចជាងវិទ្យាសាស្ត្រសង្គម

ញ៉េប សំណាង*[១] ផុន ស្រីណុម[២] និង ស្រី និង ឈូវ សុខេង[៣]

*វិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសព្រះរាជសម្ភារ

បានទទួល៖ ០១ មករា ២០២២ បោះពុម្ពផ្សាយ៖ ១៥ មិថុនា ២០២២

## សង្ខិត្តន័យ

តាមទិដ្ឋភាពជាក់ស្តែងយើងសង្កេតឃើញថា វិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសព្រះរាជសម្ភារមានសិស្សចូលរៀនថ្នាក់វិទ្យាសាស្ត្រសង្គមមានចំនួនច្រើនជាងសិស្សដែលរៀនថ្នាក់វិទ្យាសាស្ត្រ។ មូលហេតុនេះក្រុមស្រាវជ្រាវយើងខ្ញុំបានសិក្សាឈ្វេងយល់រកមូលហេតុមួយដែលអាចបណ្តាលមកពីទីតាំងសាលារៀន កត្តាសិស្ស កត្តាគណៈគ្រប់គ្រង កត្តាគ្រូបង្រៀន និងកត្តាសហគមន៍។ អ្នកចូលរួមសម្ភាសមានដូចជា នាយកសាលាចំនួន ០១នាក់ គ្រូបង្រៀនចំនួន០៦នាក់ អាណាព្យាបាលសិស្សចំនួន០៣នាក់ ឪពុកម្តាយសិស្សចំនួន៣នាក់ សិស្សានុសិស្សចំនួន១២នាក់។ លទ្ធផលនៃការស្រាវជ្រាវនេះបង្ហាញថា សិស្សដែលមករៀនថ្នាក់សង្គមច្រើន ដោយសារលទ្ធផលនៃការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ថ្នាក់សង្គមជាប់ច្រើនជាងថ្នាក់វិទ្យាសាស្ត្រ។

**អាគតដ្ឋាន:** ញ៉េប ស,. ផុន, ស,. ស្រីឈូវ, ស. (២០២២). មូលហេតុដែលនាំឱ្យ សិស្សនៅវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេសព្រះរាជសម្ភារចូលរៀនថ្នាក់វិទ្យាសាស្ត្រតិចជាងវិទ្យាសាស្ត្រសង្គម. *កាលិកបត្រអប់រំកម្ពុជា,* ៥(១),៤៧-៦០។

## ១.សេចក្តីផ្តើម

ការអភិវឌ្ឍកម្មវិធីសិក្សាជាបញ្ហាមួយយ៉ាងសំខាន់នៅក្នុងសង្គមជាតិនីមួយៗដើម្បីបង្កើនគុណភាព និងប្រសិទ្ធភាពនៃការអប់រំ។ ផែនការយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤ ឆ្នាំ ២០១៨ របស់រាជរដ្ឋាភិបាលជាត្រីវិស័យមួយនៅក្នុងការកំណត់គោលដៅអប់រំជាតិ។ គោលនយោបាយសម្រាប់អនុវត្តកម្មវិធីសិក្សាចំណេះទូទៅមានរយៈពេល ១២ឆ្នាំ ឱ្យស្របទៅនឹងការរីកចម្រើននៃវិស័យសេដ្ឋកិច្ចសង្គមកិច្ច វប្បធម៌ ។ល។ យោងលិខិតលេខ៣៦៤៤ អយក អកស រាជធានីភ្នំពេញចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១១ ជម្រាបមកលោក លោកស្រី ប្រធានមន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត កម្មវត្ថុស្តីពី"ការអនុវត្តកម្មវិធីសិក្សាថ្មីចំណេះទូទៅថ្នាក់ទី១១ និងទី១២" ក្រសួងអប់រំ យុវជន និងកីឡា បាននិងកំពុងអនុវត្តកម្មវិធីសិក្សាថ្នាក់វិទ្យាសាស្ត្រសង្គម និងថ្នាក់វិទ្យាសាស្ត្រ នៅកម្រិតវិទ្យាល័យចាប់ពីថ្នាក់ទី១១ និងថ្នាក់ទី១២។ ថ្នាក់វិទ្យាសាស្ត្រជាមុខវិជ្ជាដែលផ្តោតសំខាន់ទៅលើគណិតវិទ្យា រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា ឬមុខវិជ្ជាដែលពាក់ព័ន្ធខាងវិទ្យាសាស្ត្រ។ រីឯថ្នាក់វិទ្យាសាស្ត្រសង្គម ជាមុខវិជ្ជាដែលផ្តោតសំខាន់ទៅលើខាងមេរៀនដែលពាក់ព័ន្ធនិងមុខវិជ្ជាសង្គមដូចជា អក្សរសាស្ត្រខ្មែរ ប្រវត្តិវិទ្យា ភូមិវិទ្យា ពលរដ្ឋវិជ្ជាជាដើម។

ក្នុងការសិក្សាពីមួយឆ្នាំទៅមួយឆ្នាំសិស្សានុសិស្សបានចាប់អារម្មណ៍ទៅលើថ្នាក់វិទ្យាសាស្ត្រសង្គមជាងថ្នាក់វិទ្យាសាស្ត្រដែលជាហេតុធ្វើឱ្យបរិមាណសិស្សរៀននៅថ្នាក់វិទ្យាសាស្ត្រមានការថយចុះជាពិសេសនៅកម្រិតសិក្សាថ្នាក់ទី១២។ រីឯលទ្ធផលនៃការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិក៏បានលទ្ធផលខុសគ្នាដែរ ដោយភាគរយថ្នាក់វិទ្យាសាស្ត្រសង្គមមានអត្រាខ្ពស់ជាងថ្នាក់វិទ្យាសាស្ត្រ។ បើផ្អែកតាមដ្យាក្រាមខាងក្រោម អត្រាប្រឡងជាប់មធ្យមសិក្សាទុតិយភូមិនៃសាលាធនធានទាំង៥០នៅទូទាំងប្រទេសក្នុងឆ្នាំសិក្សា២០២១-២០២២ នោះក៏បានបង្ហាញថា សន្ទុះភាគរយនៃថ្នាក់វិទ្យាសាស្ត្រសង្គម ជារួមនៅតែមានភាគរយខ្ពស់ជាងថ្នាក់វិទ្យាសាស្ត្រដដែល បើទោះបីមានខេត្តមួយចំនួនថ្នាក់វិទ្យាសាស្ត្រមានអត្រាភាគរយខ្ពស់យ៉ាងណាក៏ដោយ(**រូបទី១**)។

**តារាងដ្យាក្រាមទី១**



ការជ្រើសរើសថ្នាក់វិទ្យាសាស្ត្រ ឬថ្នាក់វិទ្យាសាស្ត្រសង្គមរបស់សិស្សបានក្លាយជាបណ្ដុំនៃបញ្ហាមួយដែលមានការចាប់អារម្មណ៍និងត្រូវឈ្វេងយល់ពីដើមចម។ ជុំវិញបរិបទនេះ ទើបអ្នកស្រាវជ្រាវបានកំណត់ជាប្រធានបទស្ដីពី **"មូលហេតុដែលនាំឱ្យសិស្សនៅវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេសព្រះរាជសម្ភារចូលរៀនថ្នាក់វិទ្យាសាស្ត្រតិចជាងវិទ្យាសាស្ត្រសង្គម"**។ ការស្រាវជ្រាវនេះធ្វើឡើងក្នុងគោលបំណងឈ្វេងយល់ពីមូលហេតុចម្បងដែលជំរុញឱ្យសិស្សនៅវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសព្រះរាជសម្ភារទៅជ្រើសរើសថ្នាក់វិទ្យាសាស្ត្រសង្គមច្រើនជាងថ្នាក់វិទ្យាសាស្ត្រ(**តារាងស្ថិតិទី១**)។

**តារាងទី១ ៖ ស្ថិតិសិស្សទី១២ តាមឆ្នាំសិក្សា**

| ឆ្នាំសិក្សា | វិទ្យាសាស្ត្រ | វិទ្យាសាស្ត្រសង្គម | ភាគរយ | ផ្សេងៗ |
|---|---|---|---|---|
| 2016 - 2017 | 186 | 72 | 72.09 | |
| 2017 – 2018 | 76 | 229 | 29.91 | |
| 2018 – 2019 | 26 | 132 | 16.45 | |
| 2019 -2020 | 16 | 104 | 13.33 | |
| 2020 -2021 | 32 | 72 | 30.76 | |
| 2021 - 2022 | 13 | 75 | 14.77 | |

ជុំវិញបញ្ហានៃប្រធានបទនេះក្រុមអ្នកស្រាវជ្រាវបានលើកជាសំណួរគន្លឹះសំខាន់ៗដូចខាងក្រោម៖

**សំណួរស្រាវជ្រាវ៖**

ហេតុអ្វីបានជាសិស្សនៅវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេសព្រះរាជសម្ភារចូលរៀនថ្នាក់វិទ្យាសាស្ត្រតិចជាងវិទ្យាសាស្ត្រសង្គម?

**សំណួរគន្លឹះ**

១.តើសាលារៀនបានជះឥទ្ធិពលអ្វីខ្លះដល់ការសម្រេចចិត្តរបស់សិស្ស?

២.តើគណៈគ្រប់គ្រង លោកគ្រូ អ្នកគ្រូ និងសហគមន៍មានវិធីសាស្ត្រអ្វីខ្លះដើម្បីធ្វើឱ្យសិស្សចូលរៀនថ្នាក់វិទ្យាសាស្ត្រច្រើន?

៣.តើកត្តាសិស្សអ្វីខ្លះដែលនាំឱ្យសិស្សចូលរៀនថ្នាក់វិទ្យាសាស្ត្រសង្គមច្រើន ?

៤.តើកត្តាគ្រួសារបានជះឥទ្ធិពលអ្វីខ្លះដល់ការសម្រេចចិត្តរបស់កូនក្នុងការចូលរៀនថ្នាក់សង្គម?

## ២.វិធីសាស្ត្រស្រាវជ្រាវ

ការពិភាក្សាក្រុមគឺជាការប្តូរយោបល់គ្នាទៅវិញទៅមកទៅលើបញ្ហា ឬប្រធានបទណាមួយដើម្បីបានទិន្នន័យជាក់លាក់ដែលចង់បាន។ ដោយឡែកសម្រាប់ការសិក្សាស្រាវជ្រាវនេះគឺធ្វើឡើងតាមរយៈការសម្ភាសដើម្បីប្រមូលទិន្នន័យ។ ក្រុមអ្នកស្រាវជ្រាវបានរៀបចំធ្វើចំណាត់ថ្នាក់កម្រងសំណួរដែលបានមកពីការពិភាក្សាដើម្បីត្រៀមធ្វើការសម្ភាសជាមួយអ្នកពាក់ព័ន្ធ។ ក្នុងនោះដែរយើងខ្ញុំបានកំណត់ អ្នកដែលត្រូវណាត់ជួបសម្ភាសន៍ ដោយមានលិខិតជូនដំណឹងភ្ជាប់ជាមួយតារាងបញ្ជាក់ពីពេលវេលា និងទីកន្លែងនៃការជួបសម្ភាសន៍។ ក្នុងនោះដែរក្រុមអ្នកស្រាវជ្រាវបានរៀបចំកិច្ចព្រមព្រៀងគ្រប់សមាសភាពអ្នកចូលរួម ដោយមានការចុះហត្ថលេខាច្បាស់លាស់។ ជាមួយសកម្មភាពដែលក្រុមអ្នកស្រាវជ្រាវបានធ្វើដៃគូដែលបានចូលរួមសម្ភាសន៍បានសម្តែងអារម្មណ៍សាទរចំពោះសកម្មភាពនេះ ដោយមិនមានការស្ទាក់ស្ទើរ។

សិក្សាពីបញ្ហាណាមួយប្រកបដោយភាពជោគជ័យ អ្នកសិក្សាស្រាវជ្រាវត្រូវប្រមូលទិនន្ន័យនៃបញ្ហាឱ្យបានគ្រប់ជ្រុងជ្រោយ។ ជាក់ស្តែង ដើម្បីសិក្សាប្រធានបទខាងលើឱ្យទទួលបានលទ្ធផលល្អ ក្រុមអ្នកស្រាវជ្រាវបានកំណត់ជ្រើសរើសបញ្ហាសំខាន់ៗទាំងឡាយ បន្ទាប់មកបានអនុវត្តពហុមតិយកបញ្ហាសំខាន់តែមួយ ដោយមានការឯកភាពពីសមាជិកក្នុងក្រុម។ នៅពេលកំណត់បានប្រធានបទក្រុមការងារបានប្រជុំកំណត់សមាសភាពអ្នកបានចូលរួមដើម្បីសហការគ្នាបង្កើតកម្រងសំណួរ និងរៀបចំបែងចែកសមាសភាពក្រុមសម្រាប់ប្រមូលទិន្នន័យដែលពាក់ព័ន្ធនឹងប្រធានបទ។

ខណៈពេលចុះប្រមូលទិន្នន័យ ក្រុមអ្នកស្រាវជ្រាវបានធ្វើការបែងចែកជាក្រុមសមាសភាពដាច់ៗដោយឡែក។ ពេលខ្លះក្នុងករណីចាំបាច់ដែលតម្រូវឱ្យក្រុមការងារបានប្រើទូរស័ព្ទនិងតេឡេក្រាមដើម្បីទាក់ទងពីចម្ងាយជាមួយអ្នកផ្តល់សម្ភាសន៍។ ចំពោះសមាសភាពដែលត្រូវសម្ភាសន៍រួមមាន សហគមន៍គណៈគ្រប់គ្រងសាលា លោកគ្រូ អ្នកគ្រូ អាណាព្យាបាលសិស្ស និងសិស្សានុសិស្ស។ ក្នុងនោះអ្នកដែលពាក់ព័ន្ធទាំងអស់នេះក្រុមការងារយល់ថា សុទ្ធតែអ្នកដែលអាចផ្តល់ព័ត៌មានយ៉ាងពិស្តារជុំវិញប្រធានបទ ដែលអាចទទួលយកនិងគួរឱ្យមានទំនុកចិត្ត។ ដំណើរការសម្ភាសន៍ប្រព្រឹត្តទៅដោយរលូន តែទោះជាបែបណាក៏ដោយ ក៏នៅមានឧបសគ្គតិចតួចក្នុងដំណើរការស្រាវជ្រាវនេះ ពិសេសការប្រមូលព័ត៌មានតាមទូរស័ព្ទ ឬតេឡេក្រាម។ តែទោះជាយ៉ាងណាក្រុមអ្នកស្រាវជ្រាវនៅតែព្យាយាមស្តាប់ និងកត់ត្រាយ៉ាងយកចិត្តទុកដាក់នូវពាក្យគន្លឹះ សង្ខេបគំនិតសំខាន់ៗ។

បន្ទាប់មក ក្រុមអ្នកស្រាវជ្រាវបានរៀបចំបំពេញទម្រង់គំរូទៅតាមលំដាប់លំដោយនៃខ្លឹមសារដែលចង់បានដោយពិនិត្យរកគំនិតសំខាន់ៗ និងរៀបចំចំណាត់ថ្នាក់នៃប្រព័ន្ធគំនិតនោះ ដើម្បីសម្រេចវត្ថុបំណងរបស់ប្រធានបទខាងលើ។

## ៣. លទ្ធផល និងការពិភាក្សា

នៅក្នុងការជ្រើសរើសថ្នាក់សម្រាប់សិក្សាគឺទាក់ទងទៅនឹងការសម្រេចចិត្តរបស់សិស្សម្នាក់ៗ។ ជាដំបូងសិស្សត្រូវដឹងពីសមត្ថភាពរបស់ខ្លួនឱ្យច្បាស់ ជាពិសេសត្រូវដឹងជំនាញដែលខ្លួនចង់សិក្សានិងគោលដៅការងារទៅថ្ងៃអនាគតដែលខ្លួនចង់ធ្វើ ហើយត្រូវរៀនឱ្យត្រូវជំនាញ និងចំណង់ចំណូលចិត្តដោយគិតឱ្យបានល្អិតល្អន់ជាមុនសិន មុននឹងសម្រេចចិត្តចូលរៀនថ្នាក់ណាមួយ(វិទ្យាសាស្ត្រ ឬសង្គម) ព្រោះវាទាក់ទងទៅនឹងអនាគត។

ទាក់ទងទៅនឹងការជ្រើសរើសថ្នាក់វិទ្យាសាស្ត្រ និងថ្នាក់វិទ្យាសាស្ត្រសង្គមរបស់សិស្សនេះជាលទ្ធផលគឺយើងបានធ្វើការសម្ភាសន៍ ដើម្បីស្វាបស្ទង់មតិយោបល់ជាច្រើន ដើម្បីប្រមូលបានជាតុចូលយកមកឆ្លុះបញ្ចាំងឱ្យឃើញពីកត្តាដែលជះឥទ្ធិពលលើការសម្រេចចិត្តរបស់សិស្ស ក្នុងការជ្រើសរើសថ្នាក់វិទ្យាសាស្ត្រ និងវិទ្យាសាស្ត្រសង្គមនៃវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេសព្រះរាជសម្ភារ។ កត្តាខាងក្រោមជាយោបល់ដែលត្រូវបញ្ជាក់លំអិតអំពីអ្នកពាក់ព័ន្ធមួយចំនួននៅក្នុងការសិក្សារបស់សិស្សថ្នាក់ទី១២ ដែលជ្រើសរើសយកថ្នាក់វិទ្យាសាស្ត្រសង្គមច្រើនជាងថ្នាក់វិទ្យសាស្ត្រ។

បន្ទាប់ពីបានធ្វើសកម្មភាពប្រមូលទិន្នន័យបានគ្រប់គ្រាន់ហើយគឺអាចផ្តល់នូវគំនិតដើម្បីឈានទៅរកការវិភាគបញ្ហានៃប្រធានបទខាងលើ។ ក្រុមការងារអាចដឹងពីមូលហេតុដែលសិស្សនៅវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេសព្រះរាជសម្ភារចូលរៀនថ្នាក់វិទ្យាសាស្ត្រ តិចជាងវិទ្យាសាស្ត្រសង្គមគឺអាចបណ្តាលមកពីកត្តាសំខាន់ៗមួយចំនួនដូចខាងក្រោម៖

### ៣.១.កត្តាសាលារៀន

វិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសព្រះរាជសម្ភារមានចម្ងាយពីទីរួមខេត្តកំពត ប្រហែលជា៥គីឡូម៉ែត្រ ស្ថិតនៅភូមិអរគូច ឃុំអណ្តូងខ្មែរ ក្រុងកំពត ខេត្តកំពត។ សាលារៀនជាប្រភេទសាលាធនធានដែលមានអាគារសិក្សាចំនួន១៣អាគារ ស្មើនឹង៨៨បន្ទប់ រួមទាំងមានអាគារធនធានចំនួន០១ស្មើនឹង០៨បន្ទប់ក្នុងនោះមានបន្ទប់ពិសោធន៍ចំនួន០២។ បន្ទប់ពិសោធន៍ទី១ សម្រាប់មុខវិជ្ជាគីមីវិទ្យា និងជីវវិទ្យា។ បន្ទប់ពិសោធន៍ទី២ សម្រាប់មុខវិជ្ជារូបវិទ្យា និងផែនដីវិទ្យា។

ទីតាំងសាលារៀន ដែលសិស្សសិក្សាក៏មានទំនាក់ទំនងទៅនឹងការសម្រេចចិត្តរបស់សិស្សក្នុងការជ្រើសរើសផ្នែកសិក្សារបស់ពួកគេដែរ។ បើទោះបីស្ថិតក្នុងបរិបទផ្សេងគ្នាការសិក្សាទាំងពីរនេះបានរកឃើញថា សិស្សដែលសិក្សានៅសាលារៀនក្នុងទីប្រជុំជនមានទំនោរជ្រើសរើសយកផ្នែកវិទ្យាសាស្ត្រដោយបានលើកឡើងពីហេតុផលពាក់ព័ន្ធនឹងធនធានគ្រូបង្រៀន និងសម្ភារៈសម្រាប់ដំណើរការបង្រៀននិងរៀន។ ធនធានសាលារៀន ដែលបម្រើដល់ការបង្រៀន និងរៀនក៏ត្រូវបានរកឃើញថាមានផលប៉ះពាល់ដល់ការជ្រើសរើសរបស់សិស្សនៅវិទ្យាល័យ។ សាលារៀនតូចនិងសាលារៀនមធ្យមពុំមានធនធានគ្រប់គ្រាន់សម្រាប់ដំណើរការដល់ការសិក្សាលើមុខវិជ្ជាគណិតវិទ្យា និងវិទ្យាសាស្ត្រកម្រិតខ្ពស់ ដូចសាលារៀនធំៗឡើយ ដែលជាហេតុធ្វើឱ្យមានការជ្រើសរើសយកផ្នែកវិទ្យាសាស្ត្រសង្គម។ម្យ៉ាងទៀតកង្វះគ្រូបង្រៀនផ្នែកវិទ្យាសាស្ត្រ សម្ភារៈដំណើរការបង្រៀន និងរៀនបន្ទប់ដូចជា បន្ទប់ពិសោធន៍មុខវិជ្ជាវិទ្យាសាស្ត្របានប៉ះពាល់ទៅដល់ចំណាប់អារម្មណ៍របស់សិស្សក្នុងការសិក្សាមុខវិជ្ជានេះ(នាយកដ្ឋានគោលនយោបាយ,២០២១)។ ស្របជាមួយគ្នានេះដែរ ក៏នៅមានកត្តាសំខាន់ៗមួយចំនួនទៀតដែរ។

### ៣.២.កត្តាសិស្ស

ការជ្រើសរើសថ្នាក់រៀនវាពិតជាមានសារៈសំខាន់ណាស់សម្រាប់អនាគតសិស្ស។ ជាដំបូងពួកគេត្រូវយល់ដឹងពីសមត្ថភាពរបស់ខ្លួនឱ្យបានច្បាស់លាស់ និងត្រូវដឹងពីជំនាញដែលខ្លួនចង់រៀននិងគោលដៅការងារនាពេលអនាគត ហើយត្រូវរៀនឱ្យចំជំនាញនិងចំណង់ចំណូលចិត្តថាខ្លួននឹងត្រូវសិក្សាថ្នាក់វិទ្យាសាស្ត្រឬថ្នាក់វិទ្យាសាស្ត្រសង្គម។ ដោយឡែកសម្រាប់ការសិក្សានៅថ្នាក់ទី១០មិនទាន់មានការបែងចែកមុខវិជ្ជាទេ ពោលគឺនៅសិក្សារួម។ ប៉ុន្តែ នៅពេលដែលសិស្សបន្តមកដល់ថ្នាក់ទី១១ត្រូវធ្វើការសម្រេចចិត្តដើម្បីជ្រើសរើសថ្នាក់វិទ្យាសាស្ត្រនិងវិទ្យាសាស្ត្រសង្គមក្នុងការបន្តរហូតដល់ថ្នាក់ទី១២។

ក្នុងប្រកពទិន្នន័យដែលបានសម្ភាសពីសិស្សនៅក្នុងការជ្រើសរើសថ្នាក់វិទ្យាសាស្ត្រ និងថ្នាក់វិទ្យាសាស្ត្រសង្គមបង្ហាញឱ្យឃើញពីបញ្ហាសិស្ស ដែលបានមករៀននៅថ្នាក់សង្គមច្រើនគឺបណ្តាលមកពីមូលហេតុដូចជា ពេលខ្លះសិស្សចូលរៀនតាមគ្នា ដោយមិនបានកំណត់គោលដៅច្បាស់លាស់ ការសិក្សាមិនត្រូវការចំណាយថវិកាច្រើនទៅលើការៀនគួរ ព្រោះផ្តោតសំខាន់តែលើមុខវិជ្ជាមេរៀនប៉ុណ្ណោះ។ចំណែក ការសិក្សានៅថ្នាក់វិទ្យាសាស្ត្រគឺត្រូវការចំណាយថវិការៀនគួរទៅលើមុខវិជ្ជាសំខាន់ៗមួយចំនួនដូចជា គណិត រូប គីមី ជីវៈជាដើម។ ទន្ទឹមនឹងនេះ ក៏ផ្អែកទៅលើសមត្ថភាពសិស្សខ្លួនឯង ដោយសិស្សខ្លះមិនមានមូលដ្ឋានសិក្សាមុខវិជ្ជាវិទ្យាសាស្ត្រពីថ្នាក់ក្រោម។ នាពេលកន្លងមកសិស្សបានមើលឃើញពីលទ្ធផលនៃការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ សិស្សនៅផ្នែកសង្គមជាប់ច្រើន។ ហេតុ

ផលដែលសិស្សប្រហែលជា ៨៥ ភាគរយមានទំនោរទៅជ្រើសរើសថ្នាក់វិទ្យាសាស្ត្រសង្គមច្រើនជាងថ្នាក់វិទ្យាសាស្ត្រ ដោយសារពួកគេមិនគិតពីការទទួលនិទ្ទេសល្អក្នុងការប្រឡងថ្នាក់ជាតិឡើយ ពួកគេគ្រាន់តែចង់ប្រឡងឱ្យជាប់តែប៉ុណ្ណោះ។ ចំណែកទីផ្សារការងារមួយចំនួន ពួកគាត់បានយល់ឃើញថាគេយកត្រឹមតែសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិតែប៉ុណ្ណោះ ឱ្យតែប្រឡងជាប់ការងារបានធ្វើដោយមិនកំណត់ថាថ្នាក់វិទ្យាសាស្ត្រឬសង្គមនោះទេ។ រីឯការងារល្អមួយចំនួនជាការងារធ្វើបែបវិទ្យាសាស្ត្រ ប៉ុន្តែនៅពេលដែលប្រឡងចូលក្របខណ្ឌភាគច្រើនចេញតែតែងសេចក្តីទៅវិញ(មុខវិជ្ជាវិទ្យាសាស្ត្រសង្គម)។ មួយវិញទៀត នៅតាមសកលវិទ្យាល័យមួយចំនួនពុំទាន់មានការបែងចែកប្រភេទសញ្ញាបត្រថ្នាក់វិទ្យាសាស្ត្រ និងថ្នាក់វិទ្យាសាស្ត្រសង្គមឱ្យបានច្បាស់លាស់នៅឡើយទេ ដោយសិស្សថ្នាក់វិទ្យាសាស្ត្រសង្គមក៏អាចរៀនជំនាញទាក់ទងនឹងវិទ្យាសាស្ត្របានដែរ។ តាមការសម្ភាសជាក់ស្តែងពួកគេបានបង្ហាញយ៉ាងច្បាស់ថា ៖

> *«ខ្ញុំមិនចូលរៀនខាងថ្នាក់វិទ្យាសាស្ត្រ ដោយកត្តាខ្លួនឯង ព្រោះខ្ញុំយល់ថាមានការពិបាក។ ខ្ញុំជ្រើសរើសថ្នាក់សង្គមមិនចំណាយលុយរៀនគួរ ឱ្យតែពូកែទន្ទេញមេរៀន សរសេរចម្លើយឆ្លើយសំណួរឱ្យបានច្រើនៗប្រឡងជាប់ហើយ។ រវាងថ្នាក់វិទ្យាសាស្ត្រ និងវិទ្យាសាស្ត្រសង្គម ខ្ញុំជ្រើសរើសយកថ្នាក់សង្គម ព្រោះវាងាយប្រឡងជាប់និងមានការយល់ដឹងពីបញ្ហាសង្គមបានច្រើន។ រៀនថ្នាក់វិទ្យាសាស្ត្រនិងវិទ្យាសាស្ត្រសង្គមប្រឡងជាប់ទទួលបានសញ្ញាបត្រដូចតែគ្នា។»*

### ៣.៣. កត្តាគណៈគ្រប់គ្រង កត្តាគ្រូបង្រៀន និងសហគមន៍

ក្នុងកត្តាទាំងនេះក៏បានជះឥទ្ធិពលយ៉ាងខ្លាំង ដល់សិស្សនៅក្នុងការជ្រើសរើសថ្នាក់វិទ្យាសាស្ត្រសង្គមច្រើនជាងថ្នាក់វិទ្យាសាស្ត្រដែរ។ ពេលខ្លះគណៈគ្រប់គ្រងខ្វះការជំរុញឱ្យគ្រូផ្នែកវិទ្យាសាស្ត្រផលិតសម្ភារៈឧបទ្ទេសងាយៗដើម្បីបម្រើប្រយោជន៍ដល់ការបង្រៀននិងរៀន ព្រោះវាមានលក្ខណៈរូបី ដោយភ្ជាប់ទ្រឹស្តីនិងការអនុវត្តផងដែរ។ នេះជាផ្នែកមួយនៃការទាក់ទាញសិស្សឱ្យមករៀនថ្នាក់វិទ្យាសាស្ត្រឡើងវិញ។ ការតម្រង់ទិសសិក្សារបស់សិស្សថ្នាក់ទី១២ នៅមិនទាន់បានគ្រប់ជ្រុងជ្រោយទូលំទូលាយពីមជ្ឈដ្ឋានជុំវិញនៅឡើយទេ។ ពេលខ្លះខ្វះការលើកទឹកចិត្តពីលោកគ្រូ អ្នកគ្រូដោយគាត់បានពន្យល់ថាវិទ្យាសាស្ត្រសង្គមប្រឡងជាប់ ដោយមិនពិបាកគិតលេខដូចវិទ្យាសាស្ត្រឱ្យតែចងចាំមេរៀនសរសេរបានល្អៗ ក៏អាចប្រលងជាប់ដែរ។ កត្តាមួយទៀតមិនបាច់រៀនគួរ សិស្សរៀនមធ្យមក៏អាចប្រឡងជាប់បានដែរ។ កត្តាទាំងនេះហើយទើបធ្វើឱ្យសិស្សងាកមករៀនថ្នាក់សង្គមច្រើន។

ចំពោះសហគមន៍វិញ ក៏មិនទាន់បានយល់ដឹងជ្រួតជ្រាបពីតម្លៃនៃការសិក្សាថ្នាក់វិទ្យាសាស្ត្រនិងវិទ្យាសាស្ត្រសង្គមនៅឡើយ ព្រោះពេលខ្លះខ្វះមធ្យោបាយក្នុងការទំនាក់ទំនងរវាងសហគមន៍និងគណៈ

គ្រប់គ្រងសាលាក្នុងការប្រឹក្សាយោបល់ស្តីពីការជ្រើសរើសថ្នាក់វិទ្យាសាស្ត្រ និងវិទ្យាសាស្ត្រសង្គមដើម្បីផ្សព្វផ្សាយដល់អាណាព្យាបាលសិស្សឱ្យពួកគាត់មានការយល់ដឹងកាន់តែច្បាស់។ បញ្ហាមួយចំនួននេះអាចទាក់ទងទៅនឹងកត្តាតម្រង់ទិសមានរយៈពេលខ្លីពេកគឺធ្វើត្រឹមថ្នាក់ទី១១។ ដូចនេះ ក្រសួងអប់រំ យុវជន និងកីឡាគួររៀបចំឱ្យមានការតម្រង់ទិសជ្រើសរើសថ្នាក់សិក្សាតាំងពីថ្នាក់ទី៩ ឬទី១០ ព្រោះពេលខ្លះសិស្សថ្នាក់ក្រោមមិនទាន់ដឹងពីថ្នាក់វិទ្យាសាស្ត្រ និងវិទ្យាសាស្ត្រសង្គមជាអ្វី? ឬមុខវិជ្ជាអ្វីខ្លះដែលត្រូវរៀននៅឡើយ។ តាមរយៈការសម្ភាសក៏បានបង្ហាញឱ្យឃើញពីព័ត៌មានមួយចំនួនដូចខាងក្រោមៈ

> *«សម្រាប់ខ្ញុំជាគណៈគ្រប់គ្រងនៃវិទ្យាល័យចំណោះទូទៅព្រះរាជសម្ភារ សិស្សមិនចូលរៀនថ្នាក់វិទ្យាសាស្ត្របណ្តាលមកពីកត្តាខ្លួនឯង ដោយមិនជឿទុកចិត្តលើសមត្ថភាពខ្លួនឯង មិនទាន់មានគោលដៅច្បាស់អាចបណ្តាលមកពីកត្តាគ្រូខ្លះៗដែរ សិស្សខ្វះការលើកទឹកចិត្ត។ សិស្សជ្រើសរើសថ្នាក់វិទ្យាសាស្ត្រ ឬ ថ្នាក់វិទ្យាសាស្ត្រសង្គម មិនបណ្តាលមកពីកម្មវិធីសិក្សាទេ ព្រោះកម្មវិធីសិក្សាមានការកំណត់ចំនួនម៉ោង កំណត់មេរៀន និងកំណត់វត្ថុបំណងច្បាស់លាស់ណាស់។ សិស្សមិនចូលរៀនថ្នាក់វិទ្យាសាស្ត្រអាចបណ្តាលមកពីកត្តាគ្រូផងដែរ ព្រោះលោកគ្រូ អ្នកគ្រូដែលជាអ្នកប្រឹក្សាអាជីពមិនបានយកចិត្តទុកដាក់ខ្ពស់ក្នុងការតម្រង់ទិសសិស្ស ពេលខ្លះធ្វើឱ្យសិស្សពិបាកសម្រេចចិត្តជ្រើសរើសថ្នាក់វិទ្យាសាស្ត្រ ឬ វិទ្យាសាស្ត្រសង្គម។ ជួនកាលទៀត សិស្សទទួលគំនាបពីគ្រូឱ្យមករៀនគួរច្រើន។ ចំពោះសាលារៀនទទួលបានលទ្ធផលប្រឡងភាគរយខ្ពស់ តាមរយៈថ្នាក់វិទ្យាសាស្ត្រសង្គម (សាលាបើកថ្នាក់សង្គម) ធ្វើឱ្យសាលារៀនជាប់ចំណាត់ល្អ ទទួលបានការកោតសរសើរពីថ្នាក់ដឹកនាំ (នាយក)។*
>
> *ចំពោះសិស្ស ខ្ញុំយល់ថា ទាំងសិស្សថ្នាក់វិទ្យាសាស្ត្រ និងថ្នាក់សង្គមមានក្តីរំភើបរីករាយពេលទទួលបានលទ្ធផលប្រឡងជាប់ (នាយក គ្រូ សហគមន៍ មាតាបិតាសិស្ស)។ ថ្នាក់វិទ្យាសាស្ត្រ និងថ្នាក់វិទ្យាសាស្ត្រសង្គមមានបរិមាណសិស្សចូលសិក្សាមិនស្មើគ្នា(ថ្នាក់វិទ្យាសាស្ត្រសិស្សតិចសង្គមសិស្សច្រើន)ជាក្តីកង្វល់ទៅអនាគតថ្នាក់វិទ្យាសាស្ត្រ និងមានបរិមាណសិស្សកាន់តែថយតិចថែមទៀត(នាយក គ្រូ)។»*

### ៣.៤. កត្តាគ្រួសារ

តាមរយៈលទ្ធផលនៃការសម្ភាសន៍បានបង្ហាញថា សិស្សទាំងថ្នាក់វិទ្យាសាស្ត្រ និងវិទ្យាសាស្ត្រសង្គមជ្រើសរើសយកបណ្តុំមុខវិជ្ជាវិទ្យាសាស្ត្រឬវិទ្យាសាស្ត្រសង្គមដោយមានការជួយណែនាំនិងមានការជំរុញពីឪពុកម្តាយ ឬបងប្អូននៅក្នុងគ្រួសារ។ ឪពុកម្តាយភាគច្រើនមិនបានចូលរួមទេ តែគាត់យល់

ស្របទៅតាមការសម្រេចចិត្តរបស់កូន ដោយហេតុថាគាត់ចង់ឱ្យកូនរៀនទៅតាមសមត្ថភាពខ្លួនឯងផ្ទាល់ និងដោយសារគាត់មានភាពមមាញឹកក្នុងការងារផ្ទាល់ខ្លួនរបស់គាត់។ ឪពុកម្តាយមួយចំនួនតូចលួចតាមដានការសិក្សារបស់កូនតាមរយៈការទំនាក់ទំនងជាមួយគ្រូបង្រៀនផ្ទាល់ (នាយកដ្ឋានគោលនយោបាយ,២០០១)។

*«ខ្ញុំឱ្យកូនចូលរៀនថ្នាក់វិទ្យាសាស្ត្រ ដោយបានពន្យល់ណែនាំថា ការរៀនថ្នាក់វិទ្យាសាស្ត្រមានតម្លៃជាងវិទ្យាសាស្ត្រសង្គម ព្រោះតម្រូវទៅតាមស្ថានភាពទីផ្សារការងារបច្ចុប្បន្ន ស្របនឹងកូនមានសមត្ថភាពគ្រប់គ្រាន់ក្នុងការចូលរៀនថ្នាក់វិទ្យាសាស្ត្រ (សម្ភាសឪពុកម្តាយជាគ្រូបង្រៀន)។ ខ្ញុំគាំទ្រវិធីសាស្ត្របង្រៀន និងសមត្ថភាពរបស់លោកគ្រូ អ្នកគ្រូ ហើយថែមទាំងបានជំរុញកូនបន្ថែមឱ្យមករៀនថ្នាក់វិទ្យាសាស្ត្រ។ កូនក៏ចូលរៀនតាមការចង្អុលបង្ហាញរបស់ខ្ញុំ។» (សម្ភាសឪពុកម្តាយជាគ្រូបង្រៀន)*

*«ខ្ញុំឱ្យកូនចូលរៀនថ្នាក់វិទ្យាសាស្ត្រសង្គមដោយយល់ថា កូនមិនមានសមត្ថភាពគ្រប់គ្រាន់ក្នុងការចូលនៅថ្នាក់វិទ្យាសាស្ត្រ និងខ្លាចកូនប្រឡងធ្លាក់ព្រោះថ្នាក់សង្គម បើតាមដឹងភាគរយនៃវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេសព្រះរាជសម្ភារមានភាគរយជាប់ច្រើន ទើបខ្ញុំជំរុញឱ្យកូនចូលរៀនថ្នាក់វិទ្យាសាស្ត្រសង្គម។» (សម្ភាសឪពុកជាគ្រូដែលមានកូនរៀននៅថ្នាក់វិទ្យាសាស្ត្រសង្គម)*

*«ខ្ញុំមិនបានដឹងពីថ្នាក់វិទ្យាសាស្ត្រ ឬ ថ្នាក់វិទ្យាសាស្ត្រសង្គមជាអ្វីទេ កូនចង់រៀនមួយណាស្រេចតែវារើសខ្លួនឯងឱ្យតែប្រឡងជាប់គ្រួសារសប្បាយហើយ។»(ឪពុកម្តាយ)*

ដូចនេះ តាមភស្តុតាងខាងលើ ការផ្តល់ប្រឹក្សាយោបល់ពី ឪពុកម្តាយ ឬអាណាព្យាបាលពិតជាបានចូលរួមចំណែកមួយផ្នែកដែរក្នុងការសម្រេចចិត្តរបស់កូនក្នុងការជ្រើសរើសចូលរៀនថ្នាក់វិទ្យាសាស្ត្រ ឬថ្នាក់សង្គម។

### ៣.៥.កត្តាផ្សេងៗ

ការអនុវត្តកម្មវិធីសិក្សានេះត្រូវបានគេមើលឃើញថា ថ្នាក់វិទ្យាសាស្ត្រសង្គមមានចំនួនភាគរយសិស្សជាប់ខ្ពស់ជាងថ្នាក់វិទ្យាសាស្ត្រ ហើយបច្ចុប្បន្នថ្នាក់វិទ្យាសាស្ត្រសង្គមបាននឹងកំពុងកើនឡើងជាលំដាប់នៅគ្រប់វិទ្យាល័យ។ ប្រការនេះហើយបានធ្វើឱ្យសិស្សភាគច្រើនចាប់យកថ្នាក់សង្គមជាជាងថ្នាក់វិទ្យាសាស្ត្រ។ សូមលើកយកផលវិជ្ជមាន និងអវិជ្ជមានដូចតទៅ៖ ផលវិជ្ជមាន សិស្សនាពេលបច្ចុប្បន្នប្រឡងមុខវិជ្ជាតិចជាងមុនគឺប្រឡង៧មុខវិជ្ជា ហើយការប្រឡងតិចធ្វើឱ្យសិស្សងាយផ្តោតលើមុខវិជ្ជាដែលត្រូវប្រឡង។ សិស្សថ្នាក់សង្គម ប្រឡងមុខវិជ្ជាមាន ភាសាខ្មែរ គណិត ភូមិវិទ្យា ប្រវត្តិវិទ្យា

សីលធម៌ពលរដ្ឋ ភាសាអង់គ្លេស ហើយកាលពីមុនមុខវិជ្ជា៤ ទៀតត្រូវចាប់ឆ្នោតយកតែមួយ។ មុខវិជ្ជាដែលត្រូវចាប់ឆ្នោតមាន រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា ផែនដីវិទ្យា។ តែបច្ចុប្បន្នមុខវិជ្ជាទាំង៤នេះគឺតម្រូវឱ្យប្រឡងតែផែនដីវិទ្យា។ ចំណែកសិស្សថ្នាក់វិទ្យាសាស្ត្រវិញប្រឡងភាសាខ្មែរ គណិតវិទ្យា រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា ផែនដីវិទ្យា។ មុខវិជ្ជាដែលចាប់ឆ្នោតនោះមាន ប្រវត្តិវិទ្យា ភូមិ វិទ្យា និងសីលធម៌ ពលរដ្ឋវិជ្ជា ផែនដីវិទ្យា។ តែបច្ចុប្បន្នមុខវិជ្ជាទាំង៤នេះ គឺតម្រូវឱ្យប្រឡងតែប្រវត្តិវិទ្យាតែប៉ុណ្ណោះ។ ជាលទ្ធផលការប្រឡងកន្លងមកសិស្សជាប់និទ្ទេស A មានការកើនឡើងជាលំដាប់ចាប់តាំងពីឆ្នាំ២០១១មក។ ការសិក្សាមុខវិជ្ជាចំនួនតិចនេះក៏ជាការតម្រង់ទិសសិស្ស ដើម្បីងាយស្រួលក្នុងការចាប់យកជំនាញផងដែរ។ ផលអវិជ្ជមាន ការប្រឡងបច្ចុប្បន្នហាក់បីដូចជាមានកំណែប្រែល្អប្រសើរជាលំដាប់ តែក្នុងនោះវាមានផលអវិជ្ជមានពេលអនាគតច្រើនជាង ជាក់ស្តែងការបែងចែកសិស្សវិទ្យាសាស្ត្រ និងសិស្សវិទ្យាសាស្ត្រសង្គមបានធ្វើឱ្យកម្រិតការយល់ដឹងរបស់សិស្សមិនទូលំទូលាយ ព្រោះមុខវិជ្ជាដែលសិស្សរៀនហើយមិនយកមកប្រឡងថ្នាក់ជាតិ ត្រូវបានសិស្សមិនចាប់អារម្មណ៍ ហើយធ្វេសប្រហែស និងអាចជាលេសមិនខិតខំរៀនសូត្រ។ ប្រការនេះកើតមានឡើងលើសិស្សថ្នាក់សង្គម ភាគច្រើនពួកគាត់ធ្វេសប្រហែសក្នុងការសិក្សាមុខវិជ្ជាវិទ្យាសាស្ត្រ ហើយកម្រិតយល់ដឹងលើវិស័យវិទ្យាសាស្ត្រគឺខ្សោយខ្លាំង។ ការបែងចែកនេះមិនត្រូវបានកំណត់មុខវិជ្ជាឡើយ សិស្សអាចបន្តថ្នាក់ឧត្តមសិក្សាគឺសិស្សថ្នាក់វិទ្យាសាស្ត្រក៏អាចរៀនសង្គម ហើយសិស្សសង្គមក៏អាចរៀនមុខវិជ្ជាវិទ្យាសាស្ត្រ។ ការធ្វើបែបនេះនាំឱ្យសិស្សខ្លះដែលចង់ប្រឡងជាប់មធ្យមសិក្សាទុតិយភូមិ (ជាប់បាក់ឌុប) ចង់រៀនថ្នាក់វិទ្យាសាស្ត្រពិបាកខ្លាំង ហើយសូម្បីតែការប្រឡងនានាក៏ទាមទារប្រឡងមុខវិជ្ជាវិទ្យាសាស្ត្រដែរ ហេតុនេះសិស្សសង្គមមិនអាចប្រកួតប្រជែងបាន។ លើសពីនេះទៀត នៅថ្ងៃអនាគតសង្គមយើងនឹងខ្វះអ្នកបច្ចេកទេសច្រើនថែមទៀត ហើយប្រទេសអភិវឌ្ឍន៍គឺជាប្រទេសដែលមានវិស័យវិទ្យាសាស្ត្ររីកចម្រើន តែនិយាយបែបនេះ មិនមែនថាមុខវិជ្ជាវិទ្យាសាស្ត្រសង្គមមិនសំខាន់នោះទេគឺសំខាន់ដូចគ្នាតែសូមឱ្យតុល្យភាព។ តាមការអង្កេតរបស់ផ្ទាល់ ភាគច្រើនសិស្សចាប់យកមុខវិជ្ជាសង្គម គាត់គិតថាខ្លួនគាត់ខ្សោយមុខវិជ្ជាគណិតវិទ្យា ហើយខ្លះទៀតគឺមិនចង់គិតច្រើនធ្វើយ៉ាងណាឱ្យតែជាប់បាក់ឌុប។ ការយល់ឃើញបែបនេះហើយ ទើបធ្វើឱ្យសិស្សសង្គមមានសមត្ថភាពកាន់តែខ្សោយជាងសិស្សវិទ្យាសាស្ត្រ។ ជាក់ស្តែងសិស្សសង្គមពិបាកនឹងយកនិទ្ទេស A ណាស់ ហើយភាគច្រើនខ្សោយលើការវិភាគគន្លឹះតក្កវិជ្ជា។ ជាសរុប ការបែងចែកសិស្សមុខវិជ្ជាវិទ្យាសាស្ត្រ និងវិទ្យាសាស្ត្រសង្គម មានផលវិជ្ជមាននិងអវិជ្ជមាន ហើយផលអវិជ្ជមានច្រើនទៅថ្ងៃអនាគតគឺចំនួនសិស្សសង្គមបាននឹងកើនឡើង ហើយអាចជាផលប៉ះពាល់ដល់សង្គមព្រោះជនជាតិយើងនឹងមិនមានអ្នកជំនាញបច្ចេកទេស និងវិទ្យាសាស្ត្រច្រើន(វិស្វករ ពេទ្យ ជាដើម)។ ហេតុនេះ

ការឱ្យសិស្សរៀនច្រើនមុខ និងប្រឡងគ្រប់មុខវិជ្ជាជាការល្អ ព្រោះដើម្បីឱ្យពួកគាត់មានសមត្ថភាពនិងចំណេះដឹងទូលំទូលាយទាំងមុខវិជ្ជាសង្គមនិងវិទ្យាសាស្ត្រ នៅកម្រិតចំណេះទូទៅ ហើយកម្រិតចំណេះដឹងមានលក្ខណៈសកល វាជាការសំខាន់ លុះដល់ពេលពួកគាត់ចាប់យកជំនាញនៅថ្នាក់ឧត្តមសិក្សា ចាំពួកគាត់សម្រួចជំនាញដែលគាត់ពេញចិត្ត ក៏មិនទាន់យឺតពេលដែរ។

## ៤. ចំណុចខ្លាំង និងចំណុចខ្សោយ

ទោះបីជាមានការខិតខំប្រឹងប្រែងប្រកបដោយស្មារតីប្រុងប្រយ័ត្នខ្ពស់នៅក្នុងការប្រមូលទិន្នន័យ និងការវិភាគទិន្នន័យ ក្រុមការងារស្រាវជ្រាវបានស្វែងយល់ឃើញថា សកម្មភាពក្រុមមានចំណុចវិជ្ជមាន និងអវិជ្ជមានរបស់ខ្លួនមួយចំនួនដូចជា៖

### ៤.១. ចំណុចវិជ្ជមាន

ក្រុមសិក្សាស្រាវជ្រាវបានសហការ សាមគ្គីភាពគ្នាបានយ៉ាងល្អបន្ទាប់ពីបានកំណត់ជ្រើសរើសប្រធានបទដោយមានការពិភាក្សាជាពហុមតិរួចមក ហើយក៏មានការរៀបចំក្រុមពិភាក្សា រៀបចំកំណត់ពេលវេលា កំណត់សមាសភាពចូលរួមសម្ភាស។ ក្រុមស្រាវជ្រាវបានរៀបចំកម្រងសំណួរទៅតាមគោលដៅសម្ភាសន៍ ដើម្បីប្រមូលព័ត៌មានឱ្យបានគ្រប់គ្រាន់និងទាន់ពេលវេលា។ សមាសភាពពាក់ព័ន្ធដែលបានចូលរួមមានការពេញចិត្ត និងសហការជាមួយក្រុមស្រាវជ្រាវដោយក្តីសប្បាយរីករាយនិងស្និទ្ធស្នាលបំផុត។

### ៤.២. ចំណុចអវិជ្ជមាន

ក្រុមការងារស្រាវជ្រាវមានពេលវេលាខ្លីសម្រាប់ការស្រាវជ្រាវប្រមូលព័ត៌មាន។ ក្រុមការងារស្រាវជ្រាវមិនបានសម្ភាសគ្រប់សមាសភាពដែលបានកំណត់ទុក។ ការប្រមូលឯកសារពិគ្រោះនៅមានកំណត់ដោយសារពេលវេលាខ្លី ហើយក្រុមការងារស្រាវជ្រាវយើងខ្ញុំក៏មានការលំបាក ព្រោះជាពេលវេលាក្នុងបរិបទជំងឺCovid-19 កំពុងរីករាលដាលក្នុងសហគមន៍ ជាហេតុធ្វើឱ្យមានការលំបាកដល់ក្រុមការងារស្រាវជ្រាវក្នុងការប្រមូលព័ត៌មានព្រោះពេលខ្លះត្រូវធ្វើការសម្ភាសពីចម្ងាយតាមរយៈទូរស័ព្ទ ឬប្រព័ន្ធ Zoom ។

## ៥. សេចក្តីសន្និដ្ឋាន និងអនុសាសន៍

តាមរយៈទិន្នន័យ និងលទ្ធផលដែលទទួលបានមកបានឆ្លុះបញ្ចាំងឱ្យឃើញថា សិស្សដែលជ្រើសរើសចូលរៀនថ្នាក់វិទ្យាសាស្ត្រសង្គមច្រើនបណ្តាលមកពីកត្តាសំខាន់ៗមួយចំនួនដូចជា កត្តា

សាលារៀន កត្តាសិស្ស កត្តាគណៈគ្រប់គ្រង កត្តាគ្រូបង្រៀន សហគមន៍ កត្តាគ្រួសារ និងកត្តារួមផ្សំផ្សេងៗទៀត។ ក្នុងចំណោមកត្តាទាំងនេះ កត្តាដែលជះឥទ្ធិពលខ្លាំងក្នុងការជ្រើសរើសថ្នាក់វិទ្យាសាស្ត្រឬសង្គមគឺកត្តាសិស្សខ្លួនឯងដោយសារគាត់មិនបានទទួលការប្រឹក្សាយោបល់គ្រប់ជ្រុងជ្រោយពីលោកគ្រូ អ្នកគ្រូ និងមជ្ឈដ្ឋានជុំវិញ។ លើសពីនេះទៀតសិស្សខ្លះតែងតែមានការព្រួយបារម្ភនៅក្នុងការជ្រើសរើសចូលរៀនថ្នាក់វិទ្យាសាស្ត ឬថ្នាក់សង្គម។ សិស្សដែលមានសមត្ថភាពខាងវិទ្យាសាស្ត្រគាត់មិនរុញរាក្នុងការចូលរៀនថ្នាក់វិទ្យាសាស្ត្រ។ ចំណែកឯសិស្សដែលមានសមត្ថភាពខ្សោយខាងវិទ្យាសាស្ត្រគាត់ជ្រើសរើសចូលរៀនថ្នាក់សង្គម ។

**៥.១.អនុសាសន៍**

ក្រោយពីបានសិក្សាស្រាវជ្រាវរកឃើញពីកត្តាដែលសិស្សជ្រើសរើសរៀនថ្នាក់វិទ្យាសាស្ត្រមានចំនួនតិចជាងថ្នាក់វិទ្យាសាស្ត្រសង្គម ក្រុមការងារស្រាវជ្រាវ សូមផ្ដល់ជាអនុសាសន៍មួយចំនួនដូចជាៈ លោកគ្រូ អ្នកគ្រូ ជាអ្នកប្រឹក្សាអាជីពត្រូវតែយកចិត្តទុកដាក់និងមានឆន្ទៈខ្ពស់បំផុតក្នុងការតម្រង់ទិស និងលើកទឹកចិត្តសិស្ស ដើម្បីឱ្យសិស្សយល់ពីតម្លៃនៃការជ្រើសរើសយកមុខវិជ្ជាវិទ្យាសាស្ត្រ និងវិទ្យាសាស្ត្រសង្គមតាមសមត្ថភាពនិងឧបនិស្ស័យដែលខ្លួនពេញចិត្ត។ ទន្ទឹមនឹងនេះដែរ លោកគ្រូ អ្នកគ្រូថ្នាក់វិទ្យាសាស្ត្រទាំងអស់ (គណិត រូប គីមី ជីវៈ និងផែនដី) ក៏ដូចជាលោកគ្រូ អ្នកគ្រូឯកទេសដទៃៗទៀតត្រូវតែបង្កើន និងពង្រឹងសមត្ថភាពទាំងចំណេះដឹងឯកទេសនិងវិធីសាស្ត្របង្រៀនដើម្បីផ្តល់ទំនុកចិត្តចំពោះសិស្សានុសិស្ស។ បន្ថែមពីនេះ គណៈគ្រប់គ្រងសាលាត្រូវមានការទំនាក់ទំនងយ៉ាងជិតស្និតជាមួយសហគមន៍ អាណាព្យាបាល មាតាបិតាសិស្ស ដើម្បីពន្យល់ដល់ពួកគាត់ឱ្យដឹងពីគុណតម្លៃនៃការជ្រើសរើសថ្នាក់វិទ្យាសាស្ត្រ និងវិទ្យាសាស្ត្រសង្គម ក្នុងការងាយស្រួលជួយចូលរួមចំណែកតម្រង់ទិសកូន។ ស្របជាមួយគ្នានេះដែរ ក៏ត្រូវជួយលើកទឹកចិត្តដល់សិស្សានុសិស្សគ្រប់គ្នាក្នុងការជ្រើសរើសរៀនថ្នាក់វិទ្យាសាស្ត្រ និងវិទ្យាសាស្ត្រសង្គមឱ្យស្របតាមសមត្ថភាព និងឧបនិស្ស័យដែលសិស្សមាន។ ទន្ទឹមនឹងនេះ ក្រសួងអប់រំ យុវជន និងកីឡាគួរតែពិចារណាទៅលើមុខវិជ្ជាមួយចំនួនក្នុងកម្មវិធីសិក្សា ដើម្បីឱ្យសិស្សផ្តល់តម្លៃឡើងវិញនៅក្នុងការប្រឡង ហើយសូមឱ្យមានការរៀបចំតម្រង់ទិសសិស្សចាប់តាំងពីថ្នាក់ទី៩ ឬទី១០ឱ្យបានយល់ដឹងពីថ្នាក់វិទ្យាសាស្ត្រ និងវិទ្យាសាស្ត្រសង្គម។ ម្យ៉ាងវិញទៀត សូមមានការផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់សហគមន៍ មាតាបិតាសិស្ស ហើយក៏សូមឱ្យសិស្សខ្លួនឯងមានជំហរមួយ ច្បាស់លាស់ក្នុងការជ្រើសរើសចូលរៀនថ្នាក់វិទ្យាសាស្ត្រ ឬសង្គមជៀសវាងការតាមមិត្តភក្តិអូសទាញ។

## ឯកសារយោង

នាយកដ្ឋានគោលនយោបាយ. (២០២១). កត្តាជះឥទ្ធិពលលើការជ្រើសរើសថ្នាក់វិទ្យាសាស្ត្រនិងសង្គមនៅកម្រិតមធ្យមសិក្សាទុតិយភូមិក្នុងប្រទេសកម្ពុជា។

នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា (២០១១). ឯកសារណែនាំការអនុវត្តកម្មវិធីសិក្សាចំណេះទូទៅថ្នាក់ទី១១ និងទី១២ ។

ការផ្សាយចេញពីនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា ( ២០១២). ស្តង់ដារកម្មវិធិសិក្សាថ្នាក់ទី១២ ។

លិខិតលេខ ២៤៥៤ អយក.សណន (ឆ្នាំ?). សេចក្ដីណែនាំស្ដីការអនុវត្តកម្មវិធីសិក្សាចំណេះទៅនៅមធ្យមសិក្សាទុតិយភូមិ ។

យោងលិខិតលេខ ៣៦៤៤ អយក អកស (១៩-១០-២០១១). ស្ដីពី " ការអនុវត្តកម្មវិធីសិក្សាថ្មីចំណេះទូទៅថ្នាក់ទី១១ និងទី១២ "PhuongSokhttps://serey.io/imageupload data/22142ef3f2fb29662143eecd9ca548adec16405(០១-១៥-២០២០)